# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមលេខ ២៨០ក្រ៦"ថ"
ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៥៥
ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៨
-សំណុំរឿងស៊ើបសួរលេខ ៤១២៤
ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨
-សំណុំរឿងជំនុំជម្រះលេខ ៤៤៤៧
ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈ ថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ដោយមានសមាសភាពជំនុំជម្រះ

### ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### <u>ដើម្បីជំនុំជម្រះ</u>

សំណុំរឿងព្រហ្មទណ្ឌលេខ៤៣៥៥ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ

១-ឈ្មោះ [redacted] វណ្ណារ៉ា ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត[redacted] រាជធានីភ្នំពេញ មុខរបរ សិស្សថ្នាក់ទី១០ ទីលំនៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ព្រឹម "រ" ម្តាយឈ្មោះ [redacted] ទ្រី "រ" នៅលីវ ទោសពីមុន គ្មាន។ ក្រៅឃុំ។

២-ឈ្មោះ [redacted] ជាងសំបាន ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ មុខរបរ សិស្ស ទីលំនៅផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] បឿន "រ" ម្តាយឈ្មោះ [redacted] ស្រីភា "រ" នៅលីវ ទោសពីមុន គ្មាន។ ក្រៅឃុំ។

៣-ឈ្មោះ [redacted] ពន្លឺ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] រាជធានីភ្នំពេញ មុខរបរ សិស្ស ទីលំនៅភូមិ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ពុក "ស" ម្តាយឈ្មោះ [redacted] ឃុំ "រ" នៅលីវ ទោសពីមុន គ្មាន។ ក្រៅឃុំ។



Scanned with CamScanner

ត្រូវចោទប្រកាន់ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ ក្រុម១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

លោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted]វណ្ណារ៉ា។

លោក [redacted]មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted]ជាងសំបាន និងឈ្មោះ [redacted] ពន្លឺ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]យាត ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ១១៥៧ ផ្លូវលំ ក្រុមទី១១ ភូមិព្រៃកគាន្ធ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

លោក [redacted]ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី។

<u>អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ</u>

-កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧និង១០នាទី នៅចំណុចវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព ដែលប្រព្រឹត្តដោយឈ្មោះ [redacted]វណ្ណារ៉ា, ឈ្មោះ [redacted] ជាងសំបាន និងឈ្មោះ [redacted] ពន្លឺ បានព្រួតគ្នាវាយទៅលើជនរងគ្រោះឈ្មោះ[redacted] ធារ៉ា ហើយជនរងគ្រោះបានដកខ្សែក្រវ៉ាត់ពីចង្កេះវាយទៅលើឈ្មោះ[redacted] វណ្ណារ៉ា ភ្លាមៗនោះឈ្មោះ [redacted] វណ្ណារ៉ា បានយកកាំបិតប៉ុងតោពីក្នុងកាបូបស្ពាយរបស់ខ្លួនកាប់ទៅលើជនរងគ្រោះបណ្តាលឱ្យរងរបួសដាច់មេដៃ ហើយអ្នកទាំងបីបានជិះម៉ូតូគេចខ្លួនបាត់ ចំណែកជនរងគ្រោះបានបញ្ជូនទៅមន្ទីរពេទ្យ ហើយដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលចាក់អង្រែក្រោម ចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញរបាយការណ៍សំយោគលេខ៤៩របក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៤២៧៦អយព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥៦៥១"វ"ជជ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

<u>នាពេលសវនាការ</u>

-បានស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted]ជាងសំបាន។

-បានស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted]ពន្លឺ។

-បានស្តាប់អំណានចម្លើយជនរងគ្រោះឈ្មោះ[redacted]ធារ៉ា។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted]ឈុនម៉េង។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] រតនា។

-បានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] វិរៈហ្វា។

-បានពិនិត្យឯកសារភស្តុតាងនានា

<u>ការនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល</u>

-ជនជាប់ចោទឈ្មោះ [redacted]វណ្ណារ៉ា អវត្តមាន។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ជាងសំបាន អវត្តមាន។

-ជនជាប់ចោទឈ្មោះ [redacted]ពន្លឺ អវត្តមាន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ឃាត អវត្តមាន។

## តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា

ក្រោយពីបានពិនិត្យភស្តុតាងក្នុងសំណុំរឿង តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ៤២៧៦អយព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដដែល។

## មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា

កូនក្តីខ្លួន និងជនរងគ្រោះធ្លាប់មានទំនាស់នឹងគ្នាច្រើនដងមកហើយ រីឯនៅថ្ងៃកើតហេតុនោះក៏មានទំនាស់នឹងគ្នាម្តងរួចមកហើយដែរ។ បន្ទាប់ពីកូនក្តីខ្លួនបានកាប់ដាច់មេដៃរបស់ជនរងគ្រោះ ជនរងគ្រោះបានដកខ្សែក្រវ៉ាត់ក្នុងកាតាបបម្រុងមកដេញវាយកូនក្តីខ្លួន។ ជនរងគ្រោះឆ្លើយថានោះជាការការពារខ្លួន ប៉ុន្តែសួរថាហេតុអ្វីខ្សែក្រវ៉ាត់របស់ជនរងគ្រោះបែរជានៅក្នុងកាតាប តែមិនមែនពាក់ជាប់នឹងខ្លួនទៅវិញ។ នេះបញ្ជាក់ឱ្យឃើញថា ជនរងគ្រោះបានដកទុកខ្សែក្រវ៉ាត់រួចជាស្រេចដើម្បីស្កាត់វ៉ៃកូនក្តីខ្លួន ឬក៏មានន័យថា ជនរងគ្រោះប្រហែលជាបានដឹងមុនថាអំពើហិង្សានេះនឹងកើតឡើង ហើយក៏ធ្វើការត្រៀមខ្លួនទុកជាមុន ឬជនរងគ្រោះនិងកូនក្តីខ្លួនប្រហែលជាណាត់គ្នាវ៉ៃគ្នាជាមុនហើយ។ ជនរងគ្រោះមានរបួសត្រឹមតែដាច់មេដៃតែប៉ុណ្ណោះ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រាលទោសឱ្យកូនក្តីខ្លួនត្រឹមកំរិតអប្បបរមានៃទោស ដែលច្បាប់បានកំណត់ ពីព្រោះជឿជាក់ថាកូនក្តីខ្លួនពិតជាចង់បានឱកាសមួយ ដើម្បីឆាប់បានកែប្រែខ្លួនសារជាថ្មីបន្តការរៀនសូត្រ ត្រលប់មកជួបជុំក្រុមគ្រួសារ និងធ្វើការតបស្នងទៅសង្គមជាតិវិញ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជាងសំបាន ថា កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧និង១០នាទី ខ្លួនត្រូវបានឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ [redacted] ឈុនម៉េង បបួលខ្លួនហូបមីនៅមុខវិទ្យាល័យចាក់អង្រែ ប៉ុន្តែមិនទាន់បានហូបផងត្រូវឈ្មោះ [redacted] ឈុនម៉េង ឱ្យខ្លួនឌុបម៉ូតូឌុបឈ្មោះ [redacted] វណ្ណារ៉ា ទៅផ្ទះ ពេលទៅដល់ជិតផ្ទះឈ្មោះ [redacted] វណ្ណារ៉ា ប្រាប់ខ្លួនថាចង់ហូបមីនៅមុខវិទ្យាល័យ ពួក



Scanned with CamScanner

ខ្លួនក៏ជិះម៉ូតូត្រឡប់មកវិញ ក៏ឃើញឈ្មោះ [redacted] ធារ៉ា និងមិត្តភក្តិ២នាក់ទៀត កំពុងឈរនៅកែងវិទ្យាល័យហ៊ុនសែនចាក់អង្រែ ភ្លាមនោះឈ្មោះ [redacted] វណ្ណារ៉ា បានហក់ពីលើម៉ូតូរួចយកកាំបិតប៉ុងតោចេញពីក្នុងកាបូបស្ពាយទៅកាប់ឈ្មោះ [redacted] ធារ៉ា ហើយឈ្មោះ [redacted] ធារ៉ា បានយកដៃឆ្វេងរង តែត្រូវចំកន្លែងណាខ្លួនមិនបានដឹងឡើយ ចំណែកឈ្មោះ [redacted] ពន្លឺ ចូលទៅជួយឃាត់ ហើយខ្លួនក៏ស្រែកឱ្យពួកគេឈប់ បន្ទាប់មកពួកគេក៏ឈប់វាយតប់គ្នា ហើយបំបែកគ្នាទៅបាត់ ចំណែកឈ្មោះ [redacted] វណ្ណារ៉ា មិនដឹងគេចខ្លួនទៅណាទេ។ បន្ទាប់មកខ្លួនក៏ឌុបឈ្មោះ [redacted] ពន្លឺ ទៅហូបមីក្នុងគោលបំណងយកម៉ូតូទៅសងឈ្មោះ [redacted] ឈុនម៉េង ហើយមិត្តភក្តិជូនខ្លួនទៅផ្ទះ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពន្លឺ ថា កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧និង០០នាទីល្ងាច ខ្លួនចេញពីសាលារៀនហ៊ុនសែនចាក់អង្រែ ទៅផ្ទះ តែខ្លួនដើរមិនទាន់ដល់ផ្ទះ ស្រាប់តែឮសម្លេងគេស្រែកថាមានគេវាយគ្នា ខ្លួនក៏បានងាកមើលឃើញឈ្មោះ [redacted] វណ្ណារ៉ា កាន់កាំបិតប៉ុងតោនៅនឹងដៃរត់កាប់ឈ្មោះ [redacted] ធារ៉ា ចំនួន១កាំបិត មិនដឹងត្រូវចំកន្លែងណាទេ។ ដោយឃើញដូច្នេះខ្លួនបានចូលទៅជួយឃាត់ ប៉ុន្តែឃាត់មិនឈ្នះទើបខ្លួនចាប់ផ្តួលឈ្មោះ [redacted] ធារ៉ា ទៅនឹងដី ហើយខ្លួនប្រលែងឈ្មោះ [redacted] ធារ៉ា ស្រាប់តែឈ្មោះ [redacted] ធារ៉ា បានងើបឡើងដកខ្សែក្រវ៉ាត់វាយខ្លួនវិញ។ បន្ទាប់មកឈ្មោះ [redacted] ជាងសំបាន បានស្រែកប្រាប់ឈ្មោះ [redacted] ធារ៉ា ថា ដៃហ្នឹងហូរឈាម ហើយជនរងគ្រោះឈប់មើល។ បន្ទាប់ពីនោះឈ្មោះ [redacted] វណ្ណារ៉ា រត់ទៅមុខសាលា ហើយឈ្មោះ [redacted] ជាងសំបាន បានហៅខ្លួនឡើងជិះម៉ូតូឌុបជូនទៅផ្ទះវិញ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ធារ៉ា ថា កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧និង១០នាទី ខ្លួនបានជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ចេញពីសាលារៀនហ៊ុនសែនចាក់អង្រែក្រោមដោយមានគ្នា៣នាក់ ដែលឈ្មោះ [redacted] រូហ្សា ជាអ្នកឌុប។ លុះជិះបានប្រហែល១០ម៉ែត្រ ក៏បានជួបនឹងឈ្មោះ [redacted] វណ្ណារ៉ា , ឈ្មោះ [redacted] ឈុនម៉េង , ឈ្មោះ [redacted] ជាងសំបាន និងឈ្មោះ [redacted] ពន្លឺ ដោយជិះម៉ូតូចំនួន២គ្រឿងម៉ាកនិច និងមួយគ្រឿងទៀតម៉ាក MSX ជិះមកឈប់ពីមុខម៉ូតូពួកខ្លួន។ បន្ទាប់មកពួកគេបានចុះពីលើម៉ូតូព្រួតគ្នាវាយពួកខ្លួន ចំណែកឈ្មោះ [redacted] វណ្ណារ៉ា បានដកកាំបិតប៉ុងតោពីកាបូបដើរសំដៅមករូបខ្លួន ហើយពេលនោះខ្លួនបានលើកដៃឆ្វេងរង ទើបបណ្តាលឱ្យដាច់ម្រាមដៃ។ បន្ទាប់មកពួកវាក៏បានជិះម៉ូតូគេចចេញបាត់ទៅ រីឯរូបខ្លួនត្រូវបានអ្នកជិតខាងនាំយកទៅមន្ទីរពេទ្យព្យាបាល។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ឈុនម៉េង ថា កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៦និង១០នាទីល្ងាច ឈ្មោះ [redacted] ធារ៉ា បានចូលក្នុងថ្នាក់រៀនរបស់ខ្លួន រួចបានដកខ្សែក្រវ៉ាត់មកវាយលើឈ្មោះ [redacted] វណ្ណារ៉ា ដោយពុំមានមូលហេតុ ដែលឈ្មោះ [redacted] ធារ៉ា ស្ថិតនៅក្នុងស្ថានភាពស្រវឹង បន្ទាប់មកក៏ត្រូវបានមិត្តរួមថ្នាក់ និងលោកគ្រូឈ្មោះ [redacted] សំណេង បានចូលមកឃាត់និងបំបែកចេញតែម្តង។ ពេលដល់ម៉ោងចេញទៅផ្ទះ ឈ្មោះ [redacted] ជាងសំបាន បានខ្ចីម៉ូតូខ្លួនក្នុងគោលបំណងឌុបឈ្មោះ [redacted] វណ្ណារ៉ា ទៅផ្ទះ ដោយពុំបានដឹងថាមានរឿងទៀតនោះទេ។ បន្ទាប់មកខ្លួនបានទៅញ៉ាំអីជាមួយឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] ដារ៉ាវិទ្ធ នៅមុខសាលាញ្ញុនសាខាចាក់អង្រែ ជាប់សាលាហ៊ុនសែនចាក់អង្រែ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] ជាងសំបាន ថានៅសាលាមានរឿងអ្វី ប៉ុន្តែឈ្មោះ [redacted] ជាងសំបាន មិន

ឆ្លើយ បន្ទាប់មកខ្លួនក៏បានឌុបឈ្មោះ [redacted] ជាងសំបាន ទៅផ្ទះ ហើយខ្លួនក៏បានជិះត្រឡប់ទៅផ្ទះវិញ។ លុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្រាប់តែសមត្ថកិច្ចបានមកហៅខ្លួនទៅសាកសួរពីដំណើររឿងហិង្សានៅកែងវិទ្យាល័យហ៊ុនសែនចាក់អង្រែ។ ខ្លួនសូមបញ្ជាក់ថា ខ្លួនពុំបានចូលរួមក្នុងការប្រព្រឹត្តអំពើហិង្សានោះទេ។

-តាមអំណានចម្លើយជនជាប់ចោទ, ជនរងគ្រោះ និងសាក្សីខាងលើ ល្មមអាចកំណត់នូវអង្គហេតុច្បាស់លាស់មួយថា នៅថ្ងៃកើតហេតុនោះមានព្រឹត្តិហេតុពីរកើតឡើង គឺព្រឹត្តិហេតុទី១ កើតឡើងវេលាម៉ោងប្រមាណ៤និង១០នាទីរសៀល នៅក្នុងថ្នាក់រៀន ដោយជនរងគ្រោះឈ្មោះ [redacted] ធារ៉ា បានចូលទៅក្នុងថ្នាក់រៀនរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ហើយដកខ្សែក្រវ៉ាត់វាយទៅលើឈ្មោះ [redacted] វណ្ណារ៉ា តែត្រូវបានលោកគ្រូឈ្មោះ [redacted] សំណាង ឃាត់បំបែកចេញ ជាហេតុនាំឱ្យឈ្មោះ [redacted] វណ្ណារ៉ា មានកំហឹងក៏បានត្រៀមកាំបិតប៉ុងតោក្នុងកាបូបរួចស្រេច ហើយក៏ឱ្យឈ្មោះ [redacted] ជាងសំបាន ឌុបទៅរង់ចាំនៅតាមផ្លូវ នាំឱ្យកើតព្រឹត្តិហេតុទី២ វេលាម៉ោងប្រហែល៥ល្ងាច នៅមុខសាលាវិទ្យាល័យហ៊ុនសែនចាក់អង្រែ ដោយជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ដកយកកាំបិតប៉ុងតោពីកាបូបស្ពាយចូលទៅកាប់ជនរងគ្រោះឈ្មោះ [redacted] ធារ៉ា ហើយជនរងគ្រោះលើកដៃរងបណ្តាលឱ្យដាច់ម្រាមដៃ ឯឈ្មោះ [redacted] ពន្លឺ បានចូលទៅឃាត់ តែឃាត់មិនឈ្នះ ក៏ចាប់ជនរងគ្រោះផ្តួលទៅលើដី ទើបជនរងគ្រោះឈ្មោះ [redacted] ធារ៉ា យកខ្សែក្រវ៉ាត់វាយទៅលើឈ្មោះ [redacted] ពន្លឺ។

-តាមចម្លើយខាងលើ និងការពិនិត្យលើជនរងគ្រោះឈ្មោះ [redacted] ធារ៉ា ដែលដាច់មេដៃខាងឆ្វេង ព្រមទាំងការរត់គេចខ្លួនបាត់របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ពិតជាបានកាប់ទៅលើជនរងគ្រោះ បណ្តាលឱ្យពិការភាពដោយអចិន្ត្រៃយ៍ដោយដាច់មេដៃពិតប្រាកដ។ ឯជនជាប់ចោទឈ្មោះ [redacted] ពន្លឺ ពិតជាបានចូលទៅជួយវាយលើជនរងគ្រោះ ព្រមទាំងចាប់ជនរងគ្រោះផ្តួលទៅលើដីថែមទៀត ដែលអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ [redacted] ពន្លឺ ខាងលើនេះពិតជាបានរួមគ្នាប្រព្រឹត្តអំពើហិង្សាលើជនរងគ្រោះឈ្មោះ [redacted] ធារ៉ា ពិតប្រាកដ។

-ជនជាប់ចោទឈ្មោះ [redacted] ជាងសំបាន ដែលបានឌុបជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ពីថ្នាក់រៀនមករង់ចាំជនរងគ្រោះនៅមុខសាលារៀន ដោយជនជាប់ចោទឈ្មោះ [redacted] ជាងសំបាន នេះបានដឹងច្បាស់អំពីគម្រោងការរបស់ឈ្មោះ [redacted] វណ្ណារ៉ា ដោយមានការលាក់កាំបិតប៉ុងតោក្នុងកាបូប ហើយនៅពេលឈ្មោះ [redacted] វណ្ណារ៉ា កាប់ទៅលើជនរងគ្រោះនោះឈ្មោះ [redacted] ជាងសំបាន ក៏នៅទីនោះដែរ តែពុំបានហាមឃាត់ឈ្មោះ [redacted] វណ្ណារ៉ា ទេ នេះបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ជាងសំបាន ពិតជាបានជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសរបស់ឈ្មោះ [redacted] វណ្ណារ៉ា ដែលអំពើបែបនេះឆ្លើយតបតាមធាតុផ្សំក្នុងបទសមគំនិត តាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទដែលបានប្រើប្រាស់កាំបិតប៉ុងតោជាអាវុធ កនុងការកាប់ទៅលើជនរងគ្រោះបណ្តាលឱ្យដាច់មេដៃពិការភាពជាអចិន្ត្រៃយ៍ នេះឆ្លើយតបតាមធាតុផ្សំក្នុងបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព តាមមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ. ឈ្មោះ[redacted]ពន្លឺ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ជាងសំបាន ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ គឺជាអនីតិជនដែលមានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ ឃើញថា រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់ ដូចនេះជនជាប់ចោទត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់នូវអំពើរបស់ខ្លួន។

-មានភស្តុតាងគួនល្មមលើឈ្មោះ [redacted] វណ្ណារ៉ា និងឈ្មោះ[redacted]ពន្លឺ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព** ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ ក្រុម១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាងគួនល្មមលើឈ្មោះ [redacted] ជាងសំបាន ពីបទ **សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ ឬពិការភាព** ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ ក្រុម១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៨ មាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា អាយុ១៧ឆ្នាំ. ឈ្មោះ [redacted]ពន្លឺ អាយុ១៦ឆ្នាំ និងឈ្មោះ[redacted] ជាងសំបាន អាយុ១៦ឆ្នាំ ដូចនេះការផ្តន្ទាទោសលើជនជាប់ចោទរូបនេះត្រូវបន្ថយតាមលក្ខណៈនៃមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

-តាមការពិនិត្យលើអំពើរបស់ជនជាប់ចោទទាំងបី ឃើញថា ជនជាប់ចោតឈ្មោះ [redacted] វណ្ណារ៉ា ជាអ្នកប្រព្រឹត្តដោយផ្ទាល់ ដោយបានប្រើប្រាស់កាំបិតកាប់ទៅលើជនរងគ្រោះបណ្តាលឱ្យដាច់មេដៃ ហើយរត់គេចខ្លួនបាត់ ឯជនជាប់ចោទឈ្មោះ [redacted] ពន្លឺ គ្រាន់តែបានវាយដោយដៃ ឬជើង និងចាប់ផ្តួលជនរងគ្រោះទៅលើដី ឯឈ្មោះ [redacted]ជាងសំបាន គ្រាន់តែបានឌុបឈ្មោះ [redacted] វណ្ណារ៉ា ទៅកាន់កន្លែងកើតហេតុប៉ុណ្ណោះ តាមសកម្មភាពនេះឃើញថា អំពើរបស់ជនជាប់ចោទទាំងបីមានទម្ងន់ទោសខុសគ្នា ដែលគប្បីតុលាការផ្តន្ទាទោសលើជនជាប់ចោទទាំងបីក្នុងកំរិតខុសគ្នា។

-តាមទម្ងន់នៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទខាងលើ និងការរត់គេចខ្លួនរបស់ជនជាប់ចោទឈ្មោះ [redacted]ណ្ណារ៉ា គប្បីតុលាការអនុវត្តមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីការចាប់ខ្លួនជនជាប់ចោទអវត្តមានមកអនុវត្តទោស។

-ឈ្មោះ [redacted] យាត ជាម្តាយជនរងគ្រោះឈ្មោះ[redacted]ធារ៉ា បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ឯការប្តឹងទាមទារថ្លៃថ្នាំព្យាបាលចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងជំងឺចិត្តចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក គឺជាចំនួនច្រើនលើសពីការចំណាយជាក់ស្តែង និងជីវភាពរបស់ជនជាប់ចោទ ដែលគប្បីតុលាការសម្រេចត្រឹមកំរិតសមល្មម។



Scanned with CamScanner

-ជនជាប់ចោទទាំងបីបានរួមគ្នាប្រព្រឹត្តបទល្មើសជាមួយគ្នា ដូចនេះជនជាប់ចោទត្រូវទទួលខុសត្រូវលើផ្នែកសំណងរដ្ឋប្បវេណីដោយសាមគ្គីភាព។

-ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted]វណ្ណា ឈ្មោះ [redacted]ពន្លឺ ឈ្មោះ [redacted] ជាងសំបាន និងដើមបណ្តឹងរដ្ឋប្បវេណី បានទទួលដីកាកោះហៅសវនាការនេះទេ ដូចនេះសាលក្រមកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] ពន្លឺ ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជាងសំបាន ភេទប្រុស អាយុ១៦ឆ្នាំ ផ្អែកតាមមាត្រា៤៧ និងមាត្រា៥៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវធ្វើការជំនុំជម្រះនិងប្រកាសជាអសាធារណៈ។

<u>ហេតុដូច្នេះសម្រេច</u>

១-ប្រកាសពិរុទ្ធភាពលើ៖

ក.ឈ្មោះ [redacted]វណ្ណារ៉ា ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ

ខ.ឈ្មោះ [redacted]ពន្លឺ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ

ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ** ឬពិការភាព ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ ក្រុម១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

គ.ឈ្មោះ [redacted] ជាងសំបាន ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ

ពីបទ **សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារការកាត់អវៈយវៈ** ឬពិការភាព ប្រព្រឹត្តនៅចំណុចមុខវិទ្យាល័យហ៊ុនសែនចាក់អង្រែ ស្ថិតនៅផ្លូវជាតិលេខ២ ក្រុម១៨ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា២២៣ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោស៖

ក.ឈ្មោះ [redacted] វណ្ណារ៉ា ដាក់ពន្ធនាគារកំណត់រយៈពេល**០៣ឆ្នាំ០៦ខែ( បីឆ្នាំប្រាំមួយខែ )**។

ខ.ឈ្មោះ [redacted]ពន្លឺ ដាក់ពន្ធនាគារកំណត់រយៈពេល**០២ឆ្នាំ០៦ខែ( ពីរឆ្នាំប្រាំមួយខែ )**។

គ.ឈ្មោះ [redacted] ជាងសំបាន ដាក់ពន្ធនាគារកំណត់រយៈពេល**០២ឆ្នាំ០៦ខែ( ពីរឆ្នាំប្រាំមួយខែ )**។

៣-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] វណ្ណារ៉ា យកមកអនុវត្តទោសតទៅ។



Scanned with CamScanner

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ា , ឈ្មោះ [redacted] ពន្លី និងឈ្មោះ [redacted] ជាងសំបាន រួមគ្នាសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃាត ចំនួន៦០.០០០.០០០(ហុកសិបលាន)រៀល។

ការទាមទារលើសពីនេះច្រានចោល។

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈ កំបាំងមុខជនជាប់ចោទទាំង៣នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។"

រាជធានីភ្នំពេញ.ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]